# ច្បាប់កូនចៅ



កាផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

# ច្បាប់កូនចៅ

១- កូនចៅអើយស្តាប់ ឪពុកនឹងប្រាប់ ប្រដៅគ្រប់គ្នា
ចូរចាំចូរចាប់ ជាច្បាប់អាត្មា រួសរងរក្សា
ទីទៃគ្រប់ប្រាណ។

ធម្មតាអ្នកជា អ្នកមានប្រាជ្ញា មានផៀសន្តាន
ពុំបេះអាងអួត ប្រក្បួតរានកាន បំពាក់បំពាន
បំពោតអួតអង្គ។

ទោះនឹងយាត្រា ទៅទីស្ថានណា ដើរដូចភុជង្គ
សិរសាទន់ទាប សុភាពផ្គត់ផ្គង់ លំអុតអោនអង្គ
ការកេរអ្នកជា។

វីអ្នកមានសាមាន្យ ខ្សត់ខ្សោយសន្តាន អាប់ឥតប្រាជ្ញា
ដំណើរអែងអោង កែងកោងហត្ថា ដូចខ្ទួយសោះសា

# ច្បាប់កូនចៅ

មែនពិសទិប។

៨- បំពោងបំពើត បំកោងស្ងួយស្ងើត ពឹងពិសទ្រនិប
ខ្លួនតូចត្រលាំង កំលាំងសោតតិច ពឹងពិសទ្រនិប
ទិបតើប៉ុន្មាន។

ធម្មតាអ្នកជួ ពុំដែលផ្ទឹមតួ នឹងអ្នកជាបាន
ហេតុលោកការកេរ ផតពីរផ្ទឹមប្រាណ លោកការសន្ដាន
សន្ដាប់ផៅផង។

កូនចៅអើយចាំ ឪពុកនឹងផ្ដាំ ដោយនូវគន្លង
គាថាបាលី គិតពីព្រេងហោង បូរបេះចាំចង
ទីទៃកុំភ្លោយ។

ពាក្យនេះជាច្បាប់ ទុន្មានអោយគាប់ កូនចៅឯក្រោយ
ឪពុកផតទ្រព្យ អ្វីគាប់ទុកអោយ តែពាក្យនេះដោយ

# ច្បាប់កូនចៅ

ព្រះបាលីថា។

លោកថាភ្លើងភ្លឺ មែនពិតមោះរឺ ពុំស្មើសុរិយា
លោកថាសូរ្យសែង ភ្លឺបែងវេហាស៍ មោះពុំស្មើនា

ព្រះធម៌ព្រះពុទ្ធ។

១០- ភ្លើងភ្លឺអស់បិត្ត អស់កាលហើយបាត់ រលាយរលត់
ព្រះសូរ្យភ្លឺឡើង ថ្កុំថ្កើងប្រាកដ អាប់អស្តង្គត

ពុំយល់រស្មី។

វីព្រះធម៌ថ្លៃ ភ្លឺហើយភ្លឺក្រៃ នៅនាលោកិយ
ដល់បរលោកនាយ ភ្លឺឆ្លាយបារមី រុងរឿងរង្សី

ពុំរលត់ឡើយ។

កូនចៅអើយណា ពាក្យមួយលោកថា ស្ករឃ្មុំអែងហើយ
ផ្អែមក្រៃលែងផ្អែម ល្ហឹមល្ហែមជាត្រើយ មោះផ្អែមនោះស្បើយ

# ច្បាប់ក្មួនចៅ

ពុំចាប់ចាំនៅ។

តែពាក្យលោកថា លោកមានមេត្តា ទុន្នានប្រដៅ
នោះផ្អែមក្រៃលែង ស្គរឃ្មុំអំពៅ បាំបងទុកនៅ
អស់កាលដ៏លង់។

លោកថាល្វាផង សំបកក្រៅហោង ភ្លឺផ្លែកយល់យង់
រីឯក្នុងផ្លែ សឹងតែមមង់ ក្រាស់ក្រៃនៅក្នុង
នោះហោងលោកថា។

១៨- អ្នកមួយបែបប្ញវ វអែរអូវ រៀបវេរិស្សា
បញ្ចើចបញ្ចើ ពាក្យពើមាយា ដូចកលផ្លែល្វា
ល្អល្អះតែក្រៅ។

មួយដូចខ្នុរណាំង សំបកស្មោកស្មាំង បន្លាប្រុងនូវ
ឯក្នុងសឹងក្លែប ក្រអែបផ្អែមទៅ ទាល់ក្នុងឥតសៅ

# ច្បាប់ក្មួនចៅ

រសសឹងពិសា។

វីអ្នកមានធម៌ សប្បុរសមានអាថ៌ លោកផ្ទឹមឧបមា

ដូចខ្នុរក្លិនក្លែប ក្រអែបពិសា ក្រៅក្រាស់បន្លា

មោះក្នុងផ្អែមក្រៃ។

មួយសោតលោកថា កន្លង់និងផ្កា ស្អានឆ្ងាយទីទៃ

ហេតុចិត្តចង់ក្រេប ជញ្ជាប់ក្លិននៃ ហើរហួសប្រៀវប្រៃ

រសរកបុប្ផា។

ដូចអ្នកមួយមាន ចិត្តនោះចង់បាន ច្បាប់ក្បួនសាស្ត្រ

ស្វះស្វែងរកអ្នក មួយមានប្រាជ្ញា រួសរង់ឧស្សាហ៍

សង្វាតអាលដ្ឋី។

២០- មួយនឹងរុយ រករោមសំអុយ អសោចិ៍អប្រិយ

ដូចមនុស្សអបល័ក្ខណ៍ ស្វែងស្វះរកក្ដី ពុំគិតក្រក្រី

# ច្បាប់កូនចៅ

ព្រែងក្រោយឡើយនៃ។

មួយនីក្រមច្បាប់ លោកពុំអោយត្រាប់ អំពើពុតជ្រៃ
កាលណាដូចដុះ អាប់បុះអាស្រ័យ ត្រង់ស្ថានណានៃ
អ្នកដើមអន្តរាយ។

មួយនីលោកថា អំពើពុតខ្លា យល់សាប់ទាំងឡាយ
ចង់ប៉ុន្តែស៊ី ឥតបីរសាយ អស់មនុស្សទាំងឡាយ
កុំត្រាប់ពុតខ្លា។

កើតជាមនុស្សនេះ ដូចកង់រទេះ វិលត្រូវគ្រប់គ្នា
មានកាលត្រូវគេ ស្ដែងឯអាត្មា ហេតុនេះលោកថា
បើត្រាប់ពុតកង់។

វីឈើវិស័យ ដុះនៅនាព្រៃ ខ្លះវៀចខ្លះត្រង់
ឯអ្នកឥតគរ ក្សត្រក្សាន្តទ្រទ្រង់ ខ្លះបិត្តទៀងត្រង់

# ច្បាប់កូនចៅ

ខ្វះខ្លៅសាមាត្យ។

២៥- ពពួកសត្វផង សាហាវយង់ឃ្នង គេអាចញុំាងបាន
ត្រង់មនុស្សសាហាវ ពាលាឃ្លានពាន លោកអោយប្រែប្រាណ
ចៀសចេញអោយឆ្ងាយ។

កូនចៅអើយស្តាប់ ពាក្យនេះជាច្បាប់ ប្រដៅបរិយាយ
ពាក្យនេះជាថ្នល់ តំកល់ទុកឆ្ងាយ កូនចៅទាំងឡាយ
នាំគ្នាស្តាំរាំ។

ហៃអស់កូនចៅ តំណក្រោយទៅ ត្រកូលវង្សា
ចូរបេះរាប់រក ស្រករគ្នីគ្នា ខុសគាប់កាបជា
អត់អោនត្រង់រង។

អោកូនចៅអើយ អាពុកចាស់ហើយ ពុំបាននូវផង
នរណានឹងនៅ ប្រដៅបាហោង នរណានឹងស្នង

# ច្បាប់កូនចៅ

អាពុកនេះបាន។

តែខ្លួនទៅបាត់ ទុកពាក្យមួយម៉ាត់ ប្រដៅទូន្មាន

ពាក្យនេះអាពុក សង់ទុកជាស្ពាន អោយកូនចៅបាន

ឆ្លងទៅត្រើយនាយ។

៣០- ពាក្យនេះមួយមិញ ហេតុមិនស្រលាញ់ មានពាក្យថាឆ្ងាយ

ទោះទូកបែកបាក់ សំពៅធ្លុះធ្លាយ ទាល់លង្កានាយ

សឹងមករកបាន។

កូនចៅអើយគិត ផ្គត់ផ្គង់គំនិត រក្សាខ្លួនប្រាណ

កុំអាងសក្តិបុណ្យ លោភលន់បង់បាន បំពារបំពាន

កុំធ្វើដោយធម៌។

ធម្មតាជាមនុស្ស អោយដឹងគាប់ខុស បុណ្យបាបអោយស្គាល់

ប្ដីមិនបង់បាន ចង់គ្មានអង្គាល់ អោយបានដោយធម៌

នោះទើបយឺនយូរ។

បើបានឹងទំ លោភោវាយដំ សន្សំប្រាក់ចូល
បំណោះទ្រព្យនោះ នៅពុំបរិបូណ៌ ស្មើរកប្រមូល
ទុកអោយគេទេ។

កូនចៅអើយអត់ គិតក្ដីកុំសត់ កុំធ្វើប៉ោខ្វៃ
កុំអាងមានទ្រព្យ កុំត្រាប់ពុតគេ ចូរបេះរិះរេ
សាយសព្វសារពើ។

៣៨- ធម្មតាជាស្រី កុំបង់មេត្រី សាយសព្វអន្លើ
យកម្ដចទ័ណ្ឌស្ករ មកគរទុកលើ ស្រមោចហើយតើ
អត់ម្ដចមិនស៊ី។

មួយដូចប្រុសខ្លោះ ពាលពេញកំលោះ ចិត្តចោរចង់ស្រី
កលមួយដូចក្អែក ចេញល្បួចរកធី មិនដឹងរឺអ្វី

# ច្បាប់កូនចៅ

យកពងមាន់ផ្ញើ។

កលមួយសោតណា នេះនឹងឧបមា អណ្តើកអែងតើ
ពងលាក់ជាហើយ ម្តេចឡើយទៅផ្ញើ អស់ពាក្យពេចន៍លើ
អាអូតមហាចោរ។

ប្រើប្រុងប្រយ័ត្ន ពាក្យពេចន៍សួរសត្យ សាស័ព្ទពំនោល
ពីរោះមធូរ បរិបូណ៌ពាក្យពោល កុំអាលខឹងឈោះ
បាបែងភាសា។

កុំអាលកន្ទ្រើង កុំស្ថិតខិតឡើង លើលោកព្រឹទ្ធា
គិតការជំនៀល លោកដៀលនិន្ទា អង្គអោយកើតជា
និន្ទាអាស្រូវ។

៤០- ទោះប្រុសទោះស្រី កើតជាលោកិយ លោកអោយគាប់គ្រូ
ក្រែងមានផ្នេះផ្នាប ស្រលាបត្រង់ត្រូវ ក្រែងជួពុំជួ

# ច្បាប់កូនចៅ

កាលកម្មវេរា។

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា
ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា
ឆ្កួតក្រៃកន្លង។

ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង
លោកពុំអោយសេព អោយវាងតែម្តង វាតែងអោយហ្មង
ភ្លេចភ្លាំងស្មារតី។

អោយភ្លេចក្តីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាស្ត្រសួស្ដី
ភ្លេចសីលភ្លេចទាន ភ្លេចញាណវឌ្ឍី ភ្លេចច្បាប់ប្រក្រតី
ឆ្កួតបីប្រការ។

កុំអាងបំណោះ កុំអួតថាបេះ កុំដោយពុតពាល
កុំសមកុំសេព កុំស្រើបកុំស្រាល កុំអរកុំអាល

# ច្បាប់ក្មួនចៅ

ត្រេកទៅដោយវា។

៤៥- ថាបើនឹងចង់ សេពដោយបំណង់ អំពើពាលា

អាចារ្យលោកបង ជាពាក្យឧបមា អោយអ្នកមួយណា

ដុតដែកអោយក្តៅ។

បើកាន់ដែកបាន នោះទើបអោយហ៊ាន សេពសមចូលទៅ

អំពើទាំងបី ដូចដែកប្រាលផ្លៅ លុះកាន់មិនក្តៅ

នោះទើបសេពបាន។

អំពើគុណគាប់ កូនចៅអើយស្តាប់ អាពុកទូន្មាន

រៀនគុណទាំងប្រាំ សឹងនាំរូបបាន រួមរក្សាប្រាណ

ពិតពុំឃ្លាតឃ្លា។

កាលណាសឹកមាន ប្តឹងឯទាហាន ពន្លឹកមហិមា

កាលបើមានអាថិ នូវសារបញ្ហា ដោះស្រាយប្រស្នា

# ច្បាប់កូនចៅ

ថ្កើងឯប្រាជ្ញប្រាយ។

មួយសោតកាលបើ　វិះគិតនឹងធ្វើ　កិច្ចការសំទាយ
ថ្កើងឯអ្នកផង　ជំនាងសុសសាយ　កិច្ចការទំនាយ
ថ្កើងឯហោរា។

៤០- កាលកើតព្យាធី　រោគរោមឥន្ទ្រីយ　ថ្កើងឯពេទ្យា
រីអ្នកទាំងប្រាំ　សឹងនាំអាត្មា　អោយគាប់ដោយនា
បំណោះទីទៃ។

មួយសោតជាសង្ឃ　នោះអោយផ្គត់ផ្គង់　តាមព្រះវិន័យ
ជាស្រីសោតផ្គត់　មារយាទប្រពៃ　ជាមនុស្សសព្វថ្ងៃ
អោយវៀរបាបបង់។

ចូរបេះដាក់ខ្លួន　គួរគិតក្ដីស្លួន　រក្សាផ្គត់ផ្គង់
ស្គាល់ទៅស្គាល់នូវ　ប្រាជ្ញខ្មៅគប្លង់　ស្គាល់វៀបស្គាល់ត្រង់

# ច្បាប់កូនចៅ

ស្គាល់អោយគ្រប់ក្រៃ។

លោកថាអោយត្រាប់ នូវសត្វកុកសាប់ អំពើប្រពៃ

កុំត្រាប់កុកស ភោភាវសព្វថ្ងៃ ហើរទំអាស្រ័យ

ពុំប្លែកប្លែងប្រាណ។

លោកថាដែកផង ហៅរឹងកន្លង គេដុតដំបាន

រូសកោសជាការ តាមចិត្តប្រមាណ ពុំដែលនឹងមាន

ប្រកែកឡើយណា។

៥៥- ដំរីក្នុងព្រៃ សាហាវហ៊ានក្រៃ មមីសោះសា

គេទាក់មកបាន ផ្សះផ្សាំងជិះជា ពុំដែលនឹងថា

ប្រកែកមិនទៅ។

ត្រង់ពាក្យប្រទូស្ត ប្រទះរឹងរូស ពុំលុះប្រដៅ

រឹងលើសពីដែក នឹងដំរីនៅ ដោយឥតកំលៅ

# ច្បាប់ក្អមចៅ

កំលាំងមោហា។

លោកជាក្អែកពិត យកម្ដេចមណីរ័តន៍ ម្រឹគជាតិវិស័យ

កែវទៅបូជា ពាក់ម្ដេចជជា ធម្មជាតិជាស្វា

ស្លៀកម្ដេចសំពត់។

យកម្ដេចព្រះធម៌ ជ្រៅជ្រះមានអាថ៌ ប្រពៃវិសុទ្ធ

ប្រដៅពាលា ប៉ោលែស្មុតទ្រុឌ យកម្ដេចឯមកុដ

បំពាក់ពានរ។

លោកជាផ្កាផង ពិដោរពិតហោង វិស្សាបវរ

ក្លិនក្លែបត្រលប់ សាយសព្វទិសករ ហើយរោយកេសរ

បាត់បុស្បគន្ធា។

៦០- តែអ្នកមួយទៀត ពាក្យពេចន៍ឥតស្អៀង បំរើនមេត្តា

នោះកូវក្រអូប ក្រៃលែងក្លិនផ្កា ទូទៅនានា

# ច្បាប់កូនចៅ

ដោយដល់សួគ៌ស្ថាន។

រីអសោចិ៍លាមក ហៅស្អុយអាក្រក់ ពេកពន់ប្រមាណ
មោះស្អុយនោះស្បើយ ស្ហែស្ហើយគ្រាន់ក្បាន្ត ល្មមទប់ទល់បាន
ពុំទាន់ជាអ្វី។

តែអ្នកមួយកូវ រអែរអូវ ចិត្តបាបមូទូ
កុហកភរភូត បញ្ឆោតស្រដី នាំពាក្យអប្រិយ
បំបែកមិត្តគេ។

នោះកូវអាក្រក់ ស្អុយក្រៃលែងលាមក ពុំមានស្ហើយស្ហែ
ដល់បរលោកសោត ទៅនៅនិរយេ នរកអែងអែ
ទល់ទុក្ខវេទនា។

កុំពារកុំពាន កុំយល់គេមាន ប្រណែនរិស្យា
ចូរវៀរពាក្យស្លែង ថ្លែងទៅពុំជា វៀរពាក្យមុសា

# ច្បាប់កូនចៅ

បានបុណ្យក្រាស់ក្រៃ។

៦៥- កូនចៅអញអើយ　ចាំទុកជាត្រើយ　គ្រប់ខ្លួនទីទៃ
ដើរដោយគន្លង　ផ្លូវផងវិស័យ　កុំពារពានព្រៃ
ជាន់ជាប់ន្លា។

ក្រកិច្ចក្រកល　ក្រដឹងក្រយល់　ក្របិត្តសទ្ធា
ក្រវៃផ្ទៃទស់　ផ្លើយធ្លាស់លោកា　ក្រជាមាតា
បិតាស្ងួនគ្រង។

ក្រពាក្យពិរោះ　ក្របិត្តអាចស្មោះ　ដឹងទុក្ខសត្វផង
ក្រអត់ក្រអោន　ស្រលាញ់ស្ងួនគ្រង　ក្រពាក្យផតផ្លង
ល្មមនឹងបិត្តគេ។

ពាក្យស័ត្យ　ក្របិត្តអាចកាត់　ស្រលះពីស្នេហ៍
ក្រធ្ងន់គំនិត　ក្រគិតគុណគេ　ក្របានជាមេ

# ច្បាប់កូនចៅ

បាគេទាំងឡាយ។

ក្តីច្បាប់នេះក្រ    នរណាអាចយក៏    ទុកខ្លួនសំទាយ

ដ៏លោកនេះគាប់    នៅបានពណ្ណរាយ    ដល់បរលោកនាយ

សោយសុខស្រេចស្រាប់។

៧០- ឪពុកចាស់ហើយ    អស់កូនចៅអើយ    នាំគ្នាស្ដែងស្ដាប់

ពាក្យពិតទូន្មាន    ប្រធានគ្រាន់គ្រប់    ស្មើទ្រព្យសំរាប់

ទុកអោយគ្រប់គ្នា។

ចូរចាំកុំភ្លេច    ទូន្មាននេះស្រេច    ស្មើខ្លួនហើយណា

ចាំចងអោយខ្ជាប់    ជាច្បាប់អាត្មា    សូរេចអក្ខរា

សុភាសិតហោង។

--ចប់--

# ច្បាប់ក្មួនចៅ



ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ